ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តព្រះសីហនុ

សំណុំរឿងព្រហ្មទណ្ឌលេខ: ៥១២

ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២១

សំណុំរឿងស៊ើបសួរលេខ: ៣៧២ ប្រ.ក

ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២១

សំណុំរឿងជំនុំជម្រះលេខ: ៦៣

ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០២២

សាលក្រមព្រហ្មទណ្ឌលេខ: ៩៥/០៣ ក្រ១ "ក"

ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២២

ថ្ងៃព្រហស្បតិ៍ ៣រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ពស ២៥៦៦

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តព្រះសីហនុ

**បានឃើញ** ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១៨/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៨ ។

**បានឃើញ** ដីកាសម្រេចកំណត់កាលបរិច្ឆេទជំនុំជម្រះលេខ ៣៦៦៧ ត.ព.រ/២២ ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២២ របស់ប្រធានសាលាដំបូងខេត្តព្រះសីហនុ ។

បានបើកសវនាការជាសាធារណៈ នៅសាលាដំបូងខេត្តព្រះសីហនុនៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២២ វេលាម៉ោងពីរ និងសាមសិបនាទីរសៀល ដែលមានសមាសភាពចូលរួម ៖

## ក្រុមប្រឹក្សាជំនុំជម្រះ

-ឯកឧត្តម [redacted] ជាប្រធានក្រុមប្រឹក្សា

-លោក ជាចៅក្រមប្រឹក្សា

-លោកស្រី ជាចៅក្រមប្រឹក្សា

## តំណាងអយ្យការ

-លោក [redacted] ជាព្រះរាជអាជ្ញារង

## ក្រឡាបញ្ជីសវនាការ

-លោក [redacted] ជាក្រឡាបញ្ជី

**ដើម្បីជំនុំជម្រះ**

សំណុំរឿងព្រហ្មទណ្ឌលេខ ៥១២ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២១ ដែលមានជនជាប់ចោទ ៖

១- ឈ្មោះ [redacted] FU DAO ភេទប្រុស អាយុ ២៣ឆ្នាំ ជនជាតិចិន មុខរបរ ចុងភៅ ទីកន្លែងកំណើតនៅប្រទេសចិន មានទីលំនៅមុនពេលឃុំខ្លួននៅភូមិ៣ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កម្រិតវប្បធម៌ថ្នាក់ទី៩ នៅលីវ ឪពុកមិនស្គាល់ឈ្មោះ ម្តាយមិនស្គាល់ឈ្មោះ ជានីតិជន ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន ។





Scanned with CamScanner

*ត្រូវបានឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ: ៥៦៤ ត.ព.ដ/២១ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តព្រះសីហនុ ។*

ត្រូវបានចោទប្រកាន់ពីបទៈ ហិង្សាដោយចេតនា ប្រព្រឹត្តនៅភូមិ២ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ ។

២- ឈ្មោះ [redacted] PING ភេទប្រុស អាយុ ៣០ឆ្នាំ ជនជាតិចិន មុខរបរ ទេសចរណ៍ ទីកន្លែងកំណើតនៅប្រទេសចិន មានទីលំនៅមុនពេលឃុំខ្លួននៅភូមិ២ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កម្រិតវប្បធម៌ ថ្នាក់ទី៩ ប្រពន្ធឈ្មោះ [redacted] QING QING ឪពុកឈ្មោះ [redacted] ZHONG GUO (រ) ម្តាយឈ្មោះ [redacted] SHUN HUA (រ) ជានីតិជន ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន ។

*ត្រូវបានឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ: ៥៦៥ ត.ព.ដ/២១ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តព្រះសីហនុ ។*

ត្រូវបានចោទប្រកាន់ពីបទៈ រំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិ២ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ ។

**មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ៖**

១. លោកមេធាវី [redacted] មានការិយាល័យមេធាវី [redacted] អាសយដ្ឋាន ផ្ទះលេខ១៣៣E1 ផ្លូវលេខ១៣៣ សង្កាត់បឹងព្រលិត ខណ្ឌ៧មករា រាជធានីភ្នំពេញ ជាមេធាវីការពារសិទ្ធិឱ្យឈ្មោះ GUO FU DAO ។

២. លោកមេធាវី [redacted] មានការិយាល័យមេធាវី អិម អេស គី អាសយដ្ឋានបុរីភ្នំពេញ វីឡាលេខ ២៣A ផ្លូវលេខ៥ ភូមិត្រា៤ សង្កាត់ស្ទឹងមានជ័យ៣ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ជាមេធាវីការពារសិទ្ធិឱ្យឈ្មោះ [redacted] FU DAO ។

៣. លោកមេធាវី [redacted] និងកញ្ញាមេធាវី [redacted] អត្តលេខ [redacted] មានការិយាល័យក្រុមមេធាវី អ៊ីធីស៊ី សាខាខេត្តព្រះសីហនុ ទីតាំងស្ថិតនៅការិយាល័យលេខ B308 នៃអគារឆ្នេរសមុទ្រខៀវ(ឆ្នេរឯករាជ្យ) ផ្លូវ២ធ្នូ ភូមិ១ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ជាមេធាវីការពារសិទ្ធិឱ្យឈ្មោះ [redacted] PING ។

**ដើមបណ្តឹងរដ្ឋប្បវេណី៖**

ឈ្មោះ [redacted] DAN ភេទស្រី កើតឆ្នាំ១៩៨៨ ជនជាតិចិន អាសយដ្ឋានបច្ចុប្បន្ននៅភូមិ៣ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ។ (អវត្តមាន)

**មេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកមេធាវី [redacted] មានការិយាល័យមេធាវី [redacted] នៅផ្លូវ ២៨មិថុនា ភូមិ១ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ជាមេធាវីតំណាងឱ្យឈ្មោះ [redacted] DAN ។ ( អវត្តមាន)

**<u>អ្នកបកប្រែភាសា:</u>**

ឈ្មោះ [redacted] **គឹមហុង** ភេទប្រុស អាយុ ២៩ឆ្នាំ ជនជាតិខ្មែរ មានអាសយដ្ឋាននៅក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ។

## ១.អង្គហេតុនៃបណ្តឹងចោទប្រកាន់

កាលពីថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២១ នៅចំណុចខុនដូមួយកន្លែង ស្ថិតនៅភូមិ២ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ មានករណីហិង្សាដោយចេតនា បង្កឡើងដោយឈ្មោះ [redacted] FU DAO ភេទប្រុស អាយុ ២៣ឆ្នាំ ជនជាតិចិន ,ឈ្មោះ [redacted]PING ភេទប្រុស អាយុ ៣០ឆ្នាំ ជនជាតិចិន , ឈ្មោះ [redacted] HANG ភេទប្រុស អាយុ ២៦ឆ្នាំ ជនជាតិចិន ។ ដោយឈ្មោះ [redacted] FU DAO ភេទប្រុស និងឈ្មោះ [redacted] HANG ភេទប្រុស បានឡើងទៅបន្ទប់ស្នាក់នៅជនរងគ្រោះឈ្មោះ [redacted] DAN ភេទស្រី ជនជាតិចិន ពេលទៅដល់បន្ទប់នោះឈ្មោះ [redacted] FU DAO ជាក់ទ្វារបន្ទប់របស់ជនរងគ្រោះបើកចូលទៅក្នុងពេលនោះឈ្មោះ [redacted] FU DAO ចាប់ជនរងគ្រោះផ្តួលនឹងដី រួចវាយជនរងគ្រោះបណ្តាលឱ្យជាំលើផ្ទៃមុខ ចំណែកឯឈ្មោះ [redacted] HANG ជាអ្នកថតវីដេអូរសកម្មភាពវាយជនរងគ្រោះ ។ បន្ទាប់ពីធ្វើសកម្មភាពវាយលើជនរងគ្រោះរួច ឈ្មោះ [redacted] FU DAO និងឈ្មោះ [redacted]HANG ចុះមកបន្ទប់វិញ ក៏ស្រាប់តែមានឈ្មោះ [redacted] PING ភេទប្រុស បានចូលទៅបន្ទប់ជនរងគ្រោះ ឃើញជនរងគ្រោះកំពុងយំ ក៏និយាយលួងលោម ដើម្បីកុំឱ្យជនរងគ្រោះខឹង ព្រោះខ្លាចជនរងគ្រោះប្តឹងទៅលើឈ្មោះ [redacted] FU DAO ដែលបានវាយជនរងគ្រោះនោះ ។ បន្ទាប់ពីទទួលពាក្យបណ្តឹងរបស់ជនរងគ្រោះ សមត្ថកិច្ចបានធ្វើការស្រាវជ្រាវ លុះដល់ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១ ទើបធ្វើការឃាត់បានជនត្រូវចោទទាំង ០៣នាក់ខាងលើតែម្តង ។

**-បានឃើញ** ដីកាដំណោះស្រាយលេខ: ៦២១៨ ត.ព.វ/២១ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តព្រះសីហនុ ។

## ២. នាពេលសវនាការ

**២.១ ការស្តាប់ចម្លើយរបស់ជនជាប់ចោទ:**

***២.១.១ ជនជាប់ចោទឈ្មោះ[redacted] FU DAO បានឆ្លើយថា:*** សមត្ថកិច្ចឃាត់ខ្លួននៅថ្ងៃទី១៩.០៧.២០២១ ដោយសារខ្លួនវាយគ្នា ។ ពេលនោះដោយសារម្នាក់ស្រីនោះចេះតែតាមទារលុយខ្លួន ហើយខ្លួនខឹងក៏បានវាយគាត់តែម្តងទៅ ។ ខ្លួនវាយគាត់នៅម៉ុត្រីដូហ្វីន នៅបន្ទប់គាត់ស្នាក់នៅ ពេលនោះខ្លួនទៅគ្នាច្រើននាក់ តែខ្លួនចូលបន្ទប់គាត់តែម្នាក់ឯងទេ ។ ឈ្មោះ [redacted] PING ពេលខ្លួនចេញទើបគាត់ចូល ពេលទៅមានមិត្តភក្តិខ្លួនបីនាក់ទៅជាមួយ គឺឈ្មោះ [redacted] PING , ឈ្មោះ [redacted] HANG និងឈ្មោះ [redacted] DE SHENG ។ ជនរងគ្រោះជាអ្នកបើកទ្វារឱ្យពួកខ្លួន ដោយជនរងគ្រោះនៅតែទារលុយខ្លួន ខ្លួនខឹងពេកក៏បានវាយជនរងគ្រោះតែម្តង ។ ពេលខ្លួនវាយម្នាក់ស្រីនោះ គឺឈ្មោះ [redacted] HANG យកទូរស័ព្ទថត ។ ពេលមកជិះឡាន ពេលទៅវិញក៏ជិះឡាន ។ ខ្លួនជាមួយជនរងគ្រោះគ្រាន់តែអ្នកស្គាល់គ្នាទំនាក់ទំនងប្រុសស្រី ពេលកំពុងទាក់ទងជាមួយជនរងគ្រោះ ខ្លួនមានសង្សារនៅប្រទេសចិន សង្សារខ្លួន និងជនរងគ្រោះ

មិនស្គាល់គ្នាទេ ។ ជនរងគ្រោះថាបើមិនឱ្យលុយខ្លួនទេ ជនរងគ្រោះនឹងផ្ញើរបឱ្យសង្សារខ្លួននៅប្រទេសចិន ដំបូងទារប្រាក់ខ្លួនចំនួន ៦០,០០០ ដុល្លារអាមេរិក ក្រោយមកទារប្រាក់ចំនួន ៧០,០០០ ដុល្លារអាមេរិក ។ ខ្លួនវាយជនរងគ្រោះនឹងដៃ ដោយទះចំនួន ៣ ទៅ ៤ កំផ្លៀង ។ ខ្លួនស្នាក់នៅអគារតែមួយជាមួយជនរងគ្រោះ ចំពោះបីនាក់ទៀតស្នាក់នៅជាមួយគ្នាជាន់ទី១ ឈ្មោះ [redacted] PING ស្នាក់នៅក្រោម ខ្លួនស្នាក់នៅលើ ។ ពេលឡើងទៅបន្ទប់ជនរងគ្រោះ គឺមានរូបខ្លួន , ឈ្មោះ [redacted] PING និងឈ្មោះ [redacted] HANG ។ ខ្លួនមិនបានឃើញឈ្មោះ [redacted] PING វាយជនរងគ្រោះទេ ។

*៤.១.៤ ជនជាប់ចោទឈ្មោះ [redacted] PING បានឆ្លើយថា:* ពេលនោះ ខ្លួនបានទៅបន្ទប់ជនរងគ្រោះជាមួយឈ្មោះ [redacted] FU DAO ដោយទៅមានគ្នា ០៤នាក់ គឺរូបខ្លួន , ឈ្មោះ [redacted] FU DAO , ឈ្មោះ [redacted] HANG និងម្នាក់ទៀតនៅក្រៅឃុំហើយ ។ ពេលទៅដល់ ចូលក្នុងបន្ទប់មាន ០៣នាក់ ឈ្មោះ GUO FU DAO , ឈ្មោះ [redacted] HANG និងម្នាក់ទៀត ចំណែកខ្លួននៅជាន់ទី១ ពេលឈ្មោះ [redacted] FU DAO វាយជនរងគ្រោះ ខ្លួនមិននៅទេ ។ ពេលខ្លួនដឹងថាគេវាយជនរងគ្រោះ ខ្លួនក៏ឡើងទៅប្រាប់ថា កុំឱ្យវាយគេខ្លាំងពេក ព្រោះមានកាមេរ៉ា ពេលខ្លួនឡើងទៅគេវាយជនរងគ្រោះរួចហើយ ។ ពេលខ្លួនទៅដល់ អ្នកទាំងបីនាក់នេះ មិនទាន់ចេញពីបន្ទប់ជនរងគ្រោះទេ ។ ពេលខ្លួនចូលទៅ ឃើញម្នាក់ស្រីនោះរហែកអាវ ខ្លួនប្រាប់ថាឱ្យប្តូរអាវសិនទៅចាំនិយាយគ្នា ចំពោះអ្នកទាំងបីនាក់នៅក្នុងបន្ទប់នៅឡើយ បន្ទាប់មកអ្នកទាំងបីនាក់នោះក៏ចេញទៅវិញ ខ្លួននៅតែពីរនាក់ជនរងគ្រោះ ។ ខ្លួនមិនបានចាប់ជនរងគ្រោះរំលោភទេ ពេលខ្លួនចូលទៅ ឃើញសភាពជនរងគ្រោះ ច្រមុះមានស្នាមជាំ ដៃអាវរយះ តែមិនមានស្នាមរបួសទេ ។ ខ្លួននៅបន្ទប់ជាមួយជនរងគ្រោះប្រហែល ០៣នាទី តែបើគិតទាំងមានគេ និងខ្លួនចូលទៅក្នុងបន្ទប់ជនរងគ្រោះ រហូតដល់ខ្លួនចេញវិញ មានរយៈពេលប្រហែល ១០ នាទី ។ ខ្លួន និងជនរងគ្រោះ ពីមុនមិនស្គាល់គ្នាទេ ដោយសារធ្លាប់រស់នៅជាមួយគ្នា ហើយឃើញវាយគ្នា ខ្លាចមានរឿង ខ្លួនក៏ទៅឃាត់ ។ ខ្លួនដឹងថាឈ្មោះ [redacted] FU DAO ជាអ្នកស្គាល់ជនរងគ្រោះ ខ្លួនធ្លាប់ទាក់ទងជនរងគ្រោះម្តង តែខ្លួនមិនដែលទាក់ទងជនរងគ្រោះយកទៅក្រៅទេ ។ ជនរងគ្រោះមិនធ្លាប់ទាក់ទងទារប្រាក់ពីខ្លួនទេ តែធ្លាប់ឱ្យឈ្មោះ [redacted] HANG ឱ្យប្រាក់គាត់ចំនួន ២០,០០០ ដុល្លារអាមេរិក ។ ពេលឈ្មោះ [redacted] FU DAO វាយជនរងគ្រោះ ខ្លួនក៏ចូលទៅឃាត់ឱ្យឈប់វាយ តែគេវាយរួចហើយ ពេលនោះឃើញជនរងគ្រោះមានស្នាមហើម និងរហែកអាវ ។

**២.២ ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី:** *តុលាការបង្គាប់ឱ្យក្រឡាបញ្ជីអានកំណត់ហេតុស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] DAN នៅដំណាក់កាលចៅក្រមស៊ើប ដែលមានខ្លឹមសារថា:* កាលពីថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២១ ដែលជាថ្ងៃកើតហេតុ ឈ្មោះ [redacted] HANG និងបក្ខពួករបស់គេមានឈ្មោះ [redacted] FU DAO និងឈ្មោះ [redacted] PING បានឡើងគោះទ្វារបន្ទប់របស់ខ្លួននៅសណ្ឋាគារ អ៊ីលួស៊ី ស្ថិតនៅសង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ដោយពេលនោះខ្លួនមិនបានបើកទ្វារបន្ទប់ឱ្យពួកគេចូលទេ និងបានស្តីឱ្យពួកគេ

នាពេលនោះដែរ ពួកគេក៏បានដាក់ទ្វារបន្ទប់ចូលមកខាងក្នុង ដោយឈ្មោះ [redacted] HANG និង ឈ្មោះ [redacted] FU DAO បានចូលមកខាងក្នុង និងមិនបាននិយាយគ្នាទេ ហើយពេលនោះដែរ ឈ្មោះ [redacted] HANG បានបញ្ជាឱ្យឈ្មោះ [redacted] FU DAO វាយខ្លួនតែម្តង (វាយដោយដៃ) ដើម្បីឱ្យខ្លួនខូចសម្រស់ ហើយឈ្មោះ [redacted] HANG ជាអ្នកថតវីដេអូទុកគំរាមខ្លួនថែមទៀត ។ នៅពេលដែលឈ្មោះ [redacted] FU DAO កំពុងវាយខ្លួន និងឈ្មោះ [redacted] HANG កំពុងថត ស្រាប់តែឈ្មោះ [redacted] PING ដែលជាបក្ខពួករបស់ឈ្មោះ [redacted] HANG បានចូលមកឃាត់ និងដេញពួកគេទាំង ០២នាក់ចេញទៅខាងក្រៅ និងលួងលោមខ្លួន បន្ទាប់មកឈ្មោះ [redacted] PING បាននិយាយគំរាមខ្លួន ដោយនិយាយថា គេធ្លាប់សម្លាប់មនុស្ស និងបានបីខ្លួនឡើងទៅលើគ្រែ និងបានធ្វើសកម្មភាពចាប់រំលោភខ្លួន បានបញ្ចូលប្រដាប់របស់គេចូលមកក្នុងប្រដាប់ភេទរបស់ខ្លួន និងបានបញ្ចូលទឹកកាមទៅក្នុងប្រដាប់ភេទខ្លួន ដោយពេលនោះខ្លួនក៏បានស្រែក និងរើបម្រាស់ដែរ តែត្រូវឈ្មោះ [redacted] PING គំរាមសម្លាប់ខ្លួន បើខ្លួនមិនស្តាប់គេនោះទេ ថែមទាំងគំរាមមិនឱ្យខ្លួនប្តឹងសមត្ថកិច្ចផងដែរ ។ មូលហេតុដែលឈ្មោះ [redacted] HANG និងឈ្មោះ [redacted] FU DAO មករករឿង និងវាយខ្លួន ព្រោះតែខ្លួនមិនយល់ព្រមស្រលាញ់ពួកគេ ទើបគេវាយខ្លួន ហើយនៅពេលគេវាយខ្លួននោះឈ្មោះ [redacted] HANG ជាអ្នកបញ្ជាឱ្យវាយ និងជាអ្នកថតវីដេអូ ចំណែកឈ្មោះ [redacted] FU DAO ជាអ្នកវាយខ្លួនដោយដៃ (ក្តាប់ដៃ) ត្រូវចំផ្ទៃមុខ និងដងខ្លួន បច្ចុប្បន្នស្នាមរបួសជាសះស្បើយហើយ ។ ចំពោះឈ្មោះ [redacted] PING ដែលបានចាប់រំលោភខ្លួននោះ ពុំមានអ្នកឃើញឡើយ ប៉ុន្តែក្រោយពេលគេចាប់រំលោភខ្លួនរួច ក៏មានបញ្ហារោគស្ត្រី (ធ្លាក់ឈាមញឹកញាប់ និងរម៉ាស់) ដែលអាការៈទាំងនេះខ្លួនមិនធ្លាប់ជួបប្រទះពីមុនមកឡើយ ។ ចំពោះចម្លើយដែលឈ្មោះ [redacted] FU DAO បានឆ្លើយថា ខ្លួនគំរាមទារប្រាក់ពីគេ បើគេមិនឱ្យខ្លួននឹងផ្ញើវីដេអូដេកជាមួយគ្នាទៅឱ្យមិត្តស្រីរបស់គេនោះមិនពិតឡើយ ព្រោះខ្លួនមិនធ្លាប់ប៉ះពាល់លុយរបស់ពួកគេទាំង ០៣នាក់ពីមុនមកឡើយ ។ ខ្លួនទើបតែស្គាល់ឈ្មោះ [redacted] HANG មុនពេលកើតហេតុរយៈពេល ០៣ថ្ងៃ ដោយស្គាល់តាមរយៈជិះជណ្តើរយន្តជួបគ្នា ហើយគេចបានសុំលេខទូរស័ព្ទខ្លួន តែមិនធ្លាប់មានទំនាក់ទំនងអ្វីទេ ចំណែកឈ្មោះ [redacted] FU DAO និងឈ្មោះ [redacted] PING ខ្លួនមិនធ្លាប់ស្គាល់គេពីមុនមកឡើយ ។ សំណូមពរស្នើសុំតុលាការផ្តន្ទាទោសជនបង្កតាមច្បាប់ និងទាមទារសំណងចំនួន ៨០,០០០ ដុល្លារអាមេរិក ។

២.៣ ***តុលាការបង្គាប់ឱ្យក្រឡាបញ្ជីអានកំណត់ហេតុទទួលស្គាល់វត្ថុតាងចាប់យក ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១ របស់ការិយាល័យបទល្មើសព្រហ្មទណ្ឌ នៃស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ ។***

២.៤ **ការស្តាប់សេចក្តីសន្និដ្ឋានទោសរបស់តំណាងអយ្យការ:** កាលពីថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២១ ស្ថិតនៅភូមិ២ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ពិតជាមានអង្គហេតុ ហិង្សាដោយចេតនា និងរំលោភសេពសន្ថវៈ បង្កឡើងដោយឈ្មោះ [redacted] FU DAO និងឈ្មោះ [redacted] PING ប្រាកដមែន ដូច្នេះតំណាងអយ្យការស្នើសុំតម្កល់ការចោទប្រកាន់ដូចក្នុងដីកាសន្និដ្ឋានស្ថាពរទុកជាបានការដដែល ។

**២.៥ ការស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី [redacted] ការពារសិទ្ធិឱ្យជនជាប់ចោទ:** ក្រោយពីបានសួរដេញដោលក្នុងសវនាការរួចមកឃើញថា កូនក្តីខ្លួនឈ្មោះ [redacted] FU DAO បានឆ្លើយថា ខ្លួនគ្រាន់តែបានទះជនរងគ្រោះ បី ទៅ បួន កំផ្លៀងតែប៉ុណ្ណោះទេ ហើយពុំមានភស្តុតាង និងកោសល្យវិច័យនៅក្នុងរឿងនេះបញ្ជាក់ថា ជនរងគ្រោះរងរបួស រឺក៏មានសំបុត្រព្យាបាលពីមន្ទីរពេទ្យឡើយ កូនក្តីខ្លួនទើបតែប្រព្រឹត្តបទល្មើសជាលើកទី១ ហើយបន្ទាប់ពីបានឃុំឃាំងមក កូនក្តីខ្លួនដឹងកំហុស និងបានកែប្រែខ្លួនពុំប្រព្រឹត្តអំពើបែបនេះទៀតឡើយ ដូចនេះសុំក្រុមប្រឹក្សាផ្តល់ស្ថានសំរាលទោសលើកូនក្តីខ្លួនឱ្យបានទាបបំផុតផង ។

**២.៦ ការស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី [redacted] ការពារសិទ្ធិឱ្យជនជាប់ចោទ:** កូនក្តីខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់របស់តំណាងអយ្យការនោះទេ កូនក្តីខ្លួនបានបញ្ជាក់ថា ការចូលទៅក្នុងបន្ទប់គឺដើម្បីលួងលោមជនរងគ្រោះកុំឱ្យមានរឿងតែប៉ុណ្ណោះ ។ ចំពោះចម្លើយរបស់ជនរងគ្រោះ បានលើកឡើងថា កូនក្តីខ្លួនបានរំលោភ និងមានភេតស្ត្រីនោះ ពុំមានភស្តុតាងដាក់ចូលក្នុងសំណុំរឿងដូចជា កោសល្យវិច័យពេទ្យជំនាញ និងមិនមានដូចជាទឹកកាមមកបញ្ជាក់ឡើយ និងពុំមានក្រដាសស្នាមដែលបញ្ជាក់ពីមន្ទីរពេទ្យដែរ ដូច្នេះស្នើសុំតុលាការឱ្យកូនក្តីខ្លួនរួចផុតពីការចោទប្រកាន់ផង ។

**២.៧ ការស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] FU DAO :** ខ្លួនដឹងខុសហើយ សុំតុលាការមេត្តាជួយបន្ធូរបន្ថយទោសឱ្យខ្លួនផង ។

**២.៨ ការស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] PING :** សុំតុលាការឱ្យខ្លួនរួចផុតពីបទចោទប្រកាន់ផង ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់សម្តីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យភស្តុតាងនានាក្នុងសំណុំរឿង

-បានឃើញ កំណត់ហេតុជំនុំជម្រះ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តព្រះសីហនុ ។

## ៣.ផ្នែកសំអាងហេតុ

## ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ សាលាដំបូងខេត្តព្រះសីហនុ យល់ឃើញថា ៖

៣.១ តាមដីកាដំណោះស្រាយលេខ: ៦២១៨ ត.ព.រ/២១ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តព្រះសីហនុ [1] ចៅក្រមស៊ើបសួរបានសម្រេច

---

1 ដីកាដំណោះស្រាយលេខ ៦២១៨ត.ព.រ/២១ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២១ របស់សាលាដំបូងខេត្តព្រះសីហនុ ។(ឯកសារលេខ: ៦៩/៣)

ចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] FU DAO ភេទប្រុស អាយុ ២៣ឆ្នាំ ជនជាតិចិន មកជំនុំជម្រះពីបទៈ ហិង្សាដោយចេតនា ប្រព្រឹត្តនៅភូមិ២ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រាបញ្ញត្តិ ២១៧ នៃក្រមព្រហ្មទណ្ឌ និងឈ្មោះ [redacted] PING ភេទប្រុស អាយុ ៣០ឆ្នាំ ជនជាតិចិន ពីបទ រំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិ២ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ។

៣.២ អំពើល្មើសដែលរងការចោទប្រកាន់ត្រូវបានប្រព្រឹត្តឡើង នៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ ២០២១ដូច្នេះអំពើនេះត្រូវស្ថិតក្នុងវិសាលភាពនៃច្បាប់ព្រហ្មទណ្ឌ ។

៣.៣ តាមរបាយការណ៍លេខ ០៦៧/២០២១រ.ប.ក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២១[2] របស់ការិយាល័យព្រហ្មទណ្ឌ នៃកងរាជអាវុធហត្ថខេត្តព្រះសីហនុ បានបញ្ជាក់ថាៈ កាលពីថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២១ វេលាម៉ោង ១៩ និង០០នាទី នៅចំណុចអគារខុនដូរមួយកន្លែង ស្ថិតក្នុងក្រុម៩ ភូមិ១ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ មានករណី សមគំនិតអំពើហិង្សាដោយចេតនា ករណី ហិង្សាដោយចេនា ករណី រំលោភសេពសន្ថវៈ មួយកើតឡើង បង្កដោយជនសង្ស័យឈ្មោះ [redacted] HANG ភេទប្រុស អាយុ ២៦ឆ្នាំ ជនជាតិចិន ,ឈ្មោះ [redacted] FU DAO ភេទប្រុស អាយុ ២៤ឆ្នាំ ជនជាតិចិន និងឈ្មោះ [redacted] PING ភេទប្រុស អាយុ ៣០ឆ្នាំ ជនជាតិចិន បានធ្វើសកម្មភាពវាយទាត់ជាក់ ដោយប្រើដៃជើង ទៅលើជនរងគ្រោះឈ្មោះ [redacted] DAN ភេទស្រី អាយុ ៣៣ឆ្នាំ ជនជាតិចិន បណ្តាលឱ្យរបួសចំផ្ទៃមុខ ខ្នងប្រមុះ និងពេញខ្លួនប្រាណ និងបានយកទូរស័ព្ទដៃថតវីដេអូរ ដើម្បីទុកគំរាមជនរងគ្រោះ និងចាប់បង្ខំជនរងគ្រោះរំលោភ រហូតទាល់តែបានសម្រេច ខណៈពេលដែលជនរងគ្រោះ និងជនសង្ស័យឈ្មោះ [redacted] HANG ធ្លាប់មានទំនាក់ទំនងជាមួយគ្នា ហើយជនរងគ្រោះបានដឹងរឿងជនសង្ស័យមានមិត្តស្រី ម្យ៉ាងទៀត នារីម្នាក់នោះ ក៏ជាអ្នកធ្វើការជាមួយគ្នា ដោយជនសង្ស័យខ្លាចជនរងគ្រោះយករឿងទំនាក់ទំនងរបស់ខ្លួន និងជនរងគ្រោះយកទៅប្រាប់សង្សារ ព្រោះជនរងគ្រោះមានភស្តុតាងនៅក្នុងទូរស័ព្ទដៃ ទើបជនសង្ស័យប្រាប់ឲ្យជនរងគ្រោះលុបសារចេញពីទូរស័ព្ទដៃ តែជនរងគ្រោះមិនព្រមចង់ទុកជាភស្តុតាង ទើបធ្វើឲ្យជនសង្ស័យខឹង ក៏បានហៅជនសង្ស័យឈ្មោះ [redacted] FU DAO និងឈ្មោះ [redacted] PING ទៅជួបនឹងជនរងគ្រោះដល់បន្ទប់លេខ៨០១ ជាន់ទី៨ ស្ថិតក្នុងក្រុម៩ ភូមិ១ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ពេលទៅដល់ជនសង្ស័យបានទូរស័ព្ទឱ្យជនរងគ្រោះបើកទ្វារ តែជនរងគ្រោះមិន

[2] របាយការណ៍លេខ ០៦៧/២១ រ.ប.ក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២១ របស់កងរាជអាវុធហត្ថខេត្តព្រះសីហនុ ។ (ឯកសារលេខ ១)



Scanned with CamScanner

បច្ចុប្បន្នស្នាមរបួសជាសះស្បើយហើយ ។ ឈ្មោះ [redacted] FU DAO ជាអ្នកវាយខ្លួនតែម្នាក់ឯងប៉ុណ្ណោះ ។

- ផ្អែកតាមចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី និងចម្លើយរបស់ជនជាប់ចោទមានស៊ីគាពសង្វាក់គ្នា ដែលបានរំលេចឱ្យឃើញថា ជនជាប់ចោទឈ្មោះ [redacted] FU DAO ពិតជាបានប្រើហិង្សាទៅលើជនរងគ្រោះឈ្មោះ [redacted] DAN ដូចការចោទប្រកាន់ប្រាកដមែន ។

- **អំពីឈ្មោះ [redacted] PING**
  - ផ្អែកតាមចម្លើយរបស់ជនជាប់ចោទបានឆ្លើយបញ្ជាក់ថា នៅកើតហេតុខ្លួនបានឡើងទៅបន្ទប់របស់ជនរងគ្រោះក្រោយគេ ពេលខ្លួនឡើងទៅដល់ឈ្មោះ [redacted] FU DAO បានវាយជនរងគ្រោះរួចទៅហើយ ហើយខ្លួនបានឃើញជនរងគ្រោះមានសភាព រហែកអាវ ហើយយំទៀតផង បន្ទាប់មកឈ្មោះ [redacted] FU DAO និងឈ្មោះ [redacted] HANG ក៏ចេញពីបន្ទប់ជនរងគ្រោះ រួចហើយខ្លួនក៏ចូលទៅនៅក្បែរជនរងគ្រោះ ហើយនិយាយប្រាប់ឱ្យនាងប្ដូរខោអាវសិនទៅ រួចក៏និយាយលួងលោមជនរងគ្រោះបន្តិច ខ្លួនក៏ចេញពីបន្ទប់របស់ជនរងគ្រោះវិញដែរទៅ ។
  - ផ្អែកតាមចម្លើយរបស់ជនជាប់ចោទ និងពិនិត្យមើលភស្តុតាងណាមួយនៅក្នុងសំណុំរឿង តុលាការយល់ឃើញថា ពុំមានភស្តុតាងគ្រប់គ្រាន់ដើម្បីដាក់បន្ទុកលើជនជាប់ចោទពីបទ រំលោភសេពសន្ថវៈ នោះទេ ដោយហេតុថា នៅថ្ងៃកើតហេតុ ជនជាប់ចោទគ្រាន់តែទៅបន្ទប់ជនរងគ្រោះ ដើម្បីជួយឃាត់ និងលួងលោមជនរងគ្រោះកុំឱ្យមានការឈ្លោះប្រកែកវាយតប់គ្នាតែប៉ុណ្ណោះ មួយវិញទៀត តាមចម្លើយរបស់ឈ្មោះ [redacted] FU DAO បានបញ្ជាក់ថា ខ្លួនក៏ពុំបានឃើញឈ្មោះ [redacted] PING ចាប់រំលោភទៅលើជនរងគ្រោះនោះដែរ ។
  - យ៉ាងណាមិញ ផ្អែកតាមចម្លើយរបស់ដើមបណ្ដឹងបានឆ្លើយថា ខ្លួនត្រូវបានឈ្មោះ [redacted] PING ចាប់រំលោភសេពសន្ថវៈមកលើខ្លួន ប៉ុន្ដែបើពិនិត្យមើលឯកសារនានានៅក្នុងសំណុំរឿង ពុំឃើញមានភស្តុតាងណាមួយ ក៏ដូចជាលទ្ធផលកោសល្យវិច័យ និងលិខិតបញ្ជាក់ផ្សេងៗដែលចេញដោយមន្ទីរពេទ្យ ដែលអាចមកបញ្ជាក់បានថា ខ្លួនត្រូវបានគេរំលោភនោះឡើយ ម្យ៉ាងទៀត នាពេលសវនាការដើមបណ្ដឹងរដ្ឋប្បវេណីក៏ពុំបានចូលមកបំភ្លឺបញ្ជាក់ជូនតុលាការនោះដែរ ដូច្នេះផ្អែកតាមមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ[3] បានបញ្ញត្តិថា " វិមតិសង្ស័យ ត្រូវបានជា

[3] មាត្រាពាក់ព័ន្ធ: មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ ។



Scanned with CamScanner

ប្រយោជន៍ដល់ជនជាប់ចោទ - ជាមួយគ្នានេះ ផ្អែកតាមមាត្រា ៣៩០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ[4] ក៏បានបញ្ញត្តិដែរថា - ប្រសិនបើតុលាការយល់ឃើញថា អំពើនោះមិនមែនជាបទល្មើសទេ ឬក៏ជនជាប់ចោទគ្មានកំហុសទេ ជនជាប់ចោទត្រូវបានរួចខ្លួនពីបទចោទ - គប្បីតុលាការឱ្យជនជាប់ចោទរួចផុតបទចោទពីបទ រំលោភសេពសន្ថវៈ ។

៣.៥ សកម្មភាពទាក់ទងនឹងហិង្សាដោយចេតនា ត្រូវបានហាមឃាត់ដោយច្បាប់របស់ប្រទេសកម្ពុជា ដូច្នេះការដែលជនជាប់ចោទបានដឹងរួចហើយថា សកម្មភាពដែលខ្លួនបានធ្វើ គឺជាអំពើខុសច្បាប់ ប៉ុន្តែខ្លួននៅតែប្រព្រឹត្តនោះ គឺពិតជាស្តែងឱ្យឃើញអំពីចេតនាទុច្ចរិតពិតប្រាកដរបស់ជនជាប់ចោទក្នុងការប្រព្រឹត្តអំពើល្មើសដែលបានចោទប្រកាន់ ។

៣.៦ យោងតាមសំអាងហេតុខាងលើ ពិតជាបង្ហាញឱ្យឃើញថា ៖

- ពិតជាមានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] FU DAO ពីបទ ហិង្សាដោយចេតនា ប្រព្រឹត្តនៅភូមិ២ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ ។
- គ្មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] PING ពីបទ រំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិ២ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌទេ ។

៣.៧ វត្ថុចាប់យករួមមានៈ ទូរស័ព្ទដៃចំនួន ០៤ គ្រឿង (ម៉ាក READMI ពណ៌ខៀវ , ម៉ាក IPHONE 6 ពណ៌ទឹកមាស , ម៉ាក IPHONE 12 ពណ៌ស និងម៉ាក HUAWEI ពណ៌ខៀវ) កុំព្យូទ័រចំនួន ០១ ពណ៌ខ្មៅ , លិខិតឆ្លងដែនចំនួន ០១ ក្បាល (ឈ្មោះ [redacted] HANG) និងកាបូបមួយមានកាតចំនួន ០៦ ជាសម្ភារៈផ្ទាល់ខ្លួន គប្បីតុលាការសម្រេចប្រគល់ឱ្យម្ចាស់ដើមយកទៅប្រើប្រាស់ធ្វើជាម្ចាស់កម្មសិទ្ធិវិញ ។ ដោយឡែក ម្សៅសថ្លា ចំនួន ៣,៥៨ ក្រាម ជាវត្ថុអាចបង្កឱ្យមានបទល្មើស និងធ្វើឱ្យគ្រោះថ្នាក់ដល់សុខភាពរបស់ប្រជាពលរដ្ឋ គប្បីតុលាការធ្វើរឹបអូសតាមច្បាប់ ។

៣.៨ នៅក្នុងរឿងនេះ ដើមបណ្តឹងរដ្ឋប្បវេណីបានប្តឹងសុំទាមទារសំណងចំនួន ៨០,០០០ ដុល្លារអាមេរិក ពីជនជាប់ចោទ ។ គប្បីតុលាការលើកយកមកពិចារណា ។

៣.៩ តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា សុំតម្កល់ការចោទប្រកាន់ដូចក្នុងដីកាសន្និដ្ឋានស្ថាពរទុកជាបានការដដែល ។ គប្បីតុលាការលើកយកមកពិចារណា ។

[4] មាត្រាពាក់ព័ន្ធៈ មាត្រា ៣៩០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។



Scanned with CamScanner

៣.១០ មេធាវី [redacted] បានធ្វើសេចក្ដីសន្និដ្ឋានថា សុំក្រុមប្រឹក្សាផ្ដល់ស្ថានសំរាលទោសលើកូនក្ដីខ្លួនឱ្យបានទាបបំផុតផង ។ គប្បីតុលាការលើកយកមកពិចារណា ។

៣.១១ មេធាវី [redacted] បានធ្វើសេចក្ដីសន្និដ្ឋានថា សុំតុលាការឱ្យកូនក្ដីខ្លួនរួចផុតពីការចោទប្រកាន់ផង ។ គប្បីតុលាការលើកយកមកពិចារណា ។

៣.១២ ជនជាប់ចោទឈ្មោះ [redacted] FU DAO បាននិយាយសំដីចុងក្រោយថា ខ្លួនដឹងខុសហើយ សុំតុលាការមេត្តាជួយបន្ធូរបន្ថយទោសឱ្យខ្លួនផង ។ គប្បីតុលាការលើកយកមកពិចារណា ។

៣.១៣ ជនជាប់ចោទឈ្មោះ [redacted] PING បាននិយាយសំដីចុងក្រោយថា សុំតុលាការលើកលែងការចោទប្រកាន់ឱ្យខ្លួនផង ។ គប្បីតុលាការលើកយកមកពិចារណា ។

៣.១៤ កម្រិតនៃទណ្ឌកម្ម ដែលមានកំណត់ក្នុងមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ មានកម្រិតចាប់ពី ០១ ឆ្នាំ ទៅ ០៣ ឆ្នាំ និងពិន័យជាប្រាក់ពី ២,០០០,០០០ រៀល ទៅ ៦,០០០,០០០ រៀល ដូច្នេះគប្បីតុលាការពិចារណាអំពីការប្រកាសទោសក្នុងកម្រិតដែលមានកំណត់នេះ ដោយពិចារណាផ្អែកលើចរិកលក្ខណៈ នៃអំពើដែលរងការចោទប្រកាន់ រួមជាមួយកាលៈទេសៈបទល្មើស និងបុគ្គលិកលក្ខណៈនៃជនជាប់ចោទស្របតាមគោលការណ៍ឯកត្តកម្មនៃទោសតាមបញ្ញត្តិមាត្រា ៩៦ នៃក្រមព្រហ្មទណ្ឌ ។

៣.១៥ យោងតាមមាត្រា ៩៧ នៃក្រមព្រហ្មទណ្ឌ ការប្រកាសមូលទោស នៅក្នុងគ្រប់ករណីដែលបទល្មើសត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារផង និងពិន័យជាប្រាក់ផង តុលាការអាចប្រកាសៈ ទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់ជាមួយគ្នា ឬ ទោសដាក់ពន្ធនាគារតែមួយមុខប៉ុណ្ណោះ ឬ ទោសពិន័យជាប្រាក់តែមួយមុខប៉ុណ្ណោះ ។ ដូច្នេះគប្បីតុលាការលើកយកមកពិចារណា ។

## ៤.ផ្នែកសេចក្ដីសម្រេចៈ

## ហេតុដូច្នេះសាលាដំបូងខេត្តព្រះសីហនុ

## វិនិច្ឆ័យសេចក្ដី

៤.១ **ឱ្យរួចខ្លួន**ពីបទចោទលើឈ្មោះ [redacted] PING ភេទប្រុស អាយុ ៣០ឆ្នាំ ជនជាតិចិន (មានសាវតារជាតិដូចខាងលើ) ៖

ពីបទ **រំលោភសេពសន្ថវៈ** ប្រព្រឹត្តនៅភូមិ២ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា **៣៥០** នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៤.២ **ផ្ដន្ទាទោស**លើឈ្មោះ [redacted] FU DAO ភេទប្រុស អាយុ ២៣ឆ្នាំ ជនជាតិចិន (មានសាវតារជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល **១៥ (ដប់ប្រាំ) ខែ ៖**



Scanned with CamScanner

ពីបទ **ហិង្សាដោយចេតនា** ប្រព្រឹត្តនៅភូមិ២ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **២១៧** និងមាត្រា **៩៧** នៃក្រមព្រហ្មទណ្ឌ ។

៤.៣ **បង្គាប់ឱ្យ**ឈ្មោះ [redacted] FU DAO ភេទប្រុស អាយុ ២៣ឆ្នាំ ជនជាតិចិន សងសំណងថ្លៃព្យាបាល និងជម្ងឺចិត្តចំនួន **៨,០០០,០០០ (ប្រាំបីលាន) រៀល** ឱ្យទៅជនរងគ្រោះឈ្មោះ [redacted] DAN ។ ការទាមទារលើសពីនេះត្រូវច្រានចោល ។

៤.៤ **បង្គាប់យកវត្ថុតាងប្រគល់ឱ្យម្ចាស់ដើមវិញ រួមមាន:**

- ទូរស័ព្ទដៃចំនួន ០៤ គ្រឿង (ម៉ាក READMI ពណ៌ខៀវ , ម៉ាក IPHONE 6 ពណ៌ទឹកមាស , ម៉ាក IPHONE 12 ពណ៌ស និងម៉ាក HUAWEI ពណ៌ខៀវ) ។
- កុំព្យូទ័រចំនួន ០១ ពណ៌ខ្មៅ ។
- លិខិតឆ្លងដែនចំនួន ០១ ក្បាល (ឈ្មោះ [redacted] HANG) ។
- កាបូបមួយមានកាតចំនួន ០៦ ។

៤.៥ **បង្គាប់យកវត្ថុតាងរឹបអូស និងបំផ្លាញចោល មាន:**

- ម្សៅសថ្នាំចំនួន ៣,៥៨ ក្រាម ។

**សាលក្រម**នេះជំនុំជម្រះនៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២២ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី ។ ទុកសិទ្ធិឱ្យប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

**ក្រឡាបញ្ជីសវនាការ**
ហត្ថលេខា និងត្រា: [redacted]

**ក្រុមប្រឹក្សាជំនុំជម្រះ**
ហត្ថលេខា និងត្រា: [redacted]

---

បានឃើញ
**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"
ថ្ងៃព្រហស្បតិ៍ ៣រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
ខេត្តព្រះសីហនុ, ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២២
**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner